## និយមន័យការរំញោច (Stimulation)

ការរំញោច គឺជាវិធីប្រើផលិតផលគីមីដើម្បីទាញយកទឹកជ័រឲ្យបានច្រើន ដោយវាមិនធ្វើឲ្យមុខសរសៃជ័រទាប់ស្ទះ និងធ្វើឲ្យទឹកជ័រហូរចេញបានយូរ។ ជាលទ្ធផល ការរំញោចធ្វើឲ្យកសិករទទួលបានជ័រកៅស៊ូច្រើន ដោយពុំចាំបាច់បង្កើនប្រវែងមុខចៀរឬចង្វាក់ចៀរ។ល។

## អត្ថប្រយោជន៍នៃការរំញោច

ការរំញោចនឹងជួយ ៖

- បង្កើនបរិមាណទឹកជ័រនៃអ្នកចៀរជ័រ ហើយស្របគ្នានោះប្រាក់កម្រៃរបស់អ្នកចៀរក៏កើនឡើង។
- ការចំណាយសម្បកអស់តិចៗ ព្រោះហេតុនេះបានជាដើមកៅស៊ូមានរយៈពេលចៀរយកជ័របានយូរឆ្នាំ។
- បន្ថយចង្វាក់ចៀរ ប៉ុន្តែអាចយកផលបានដូចចង្វាក់ញឹក ឬ បានច្រើនជាង។ ដូចនេះ គេប្រើកម្មករចំនួនតិចដែលធ្វើឲ្យសោហ៊ុយចំណាយក្នុងការប្រមូលផលថយចុះ ឯទិន្នផលនៅដដែល។
- ពន្យារការចៀរសម្បកដែលដុះថ្មីឡើងវិញ។ ដូច្នេះ សម្បកដែលដុះថ្មីនេះ មានលក្ខណៈពេញលេញ ហើយមានសភាពល្អប្រសើរ។

## អំពីល្បាយថ្នាំរំញោច

សព្វថ្ងៃថ្នាំរំញោចដែលគេនិយមប្រើច្រើនជាងគេគឺ "**អេតេហ្វូន** - Ethephon" ឬ ឈ្មោះគីមីហៅថា **អាស៊ីត ២ ក្លរ៉ូអេទីល - ផូស្វូរិក** (2 chloroethyl-phosphoric acid)។ គេអាចស្គាល់ផងដែរនូវថ្នាំរំញោចនេះ ក្រោមឈ្មោះ "**អេត្រែល** - Ethrel"។

អេតេហ្វូនត្រូវបានលាបក្រោមរូបភាពជាល្បាយជាមួយទឹក ឬ ប្រេង (ដូងប្រេង)។ លើទីផ្សារអាចមានល្បាយដែលមានកំហាប់ផ្សេងៗ (2,5%, 5%,...)។

## ការរំញោច

ការរំញោចមានច្រើនវិធី ប៉ុន្តែវិធីដែលគេច្រើនអនុវត្តគឺវិធីលាបថ្នាំរំញោចដោយប្រើជក់លាប។

### ១. វិធីលាបថ្នាំរំញោច

នៅក្នុងចំណោមវិធីលាបទាំងឡាយ វិធីលាបនៅលើសម្បកដែលដុះឡើងវិញ (panel application) ត្រូវបានគេនិយមប្រើជាងគេ។

ក្នុងករណីនេះ ថ្នាំរំញោចត្រូវបានលាបផ្ទាល់លើមុខចៀរ (tapping cut) ទៅតាមប្រវែងមុខចៀរ (ផ្ទៃលាបមានទទឹងប្រមាណ ១សង់ទីម៉ែត្រ) នៅលើសម្បកដែលដុះឡើងវិញ។

វិធីនេះមានភាពងាយស្រួល ហើយចំណាយតិចៗ ហេតុនេះហើយ វិធីនេះត្រូវបានគេអនុវត្តច្រើនជាងគេ។




មុខចៀរចុះក្រោម




មុខចៀរឡើងលើ

**វិធីលាបលើសម្បកដែលដុះឡើងវិញ**
Panel application (Eric Gohet, 2012)

## ២. កំហាប់នៃថ្នាំរំញោច

ចំពោះកំហាប់ 2,5% នៃល្បាយថ្នាំរំញោចដែលត្រូវលាប បរិមាណកំណត់ជាមធ្យម គឺ១ក្រាម សម្រាប់លាបមួយដើម សម្រាប់ការចៀរពាក់កណ្ដាលគូទខ្យង (S/2)។ ករណីចៀរឡើងលើ (1/4 SUTS) ឬចៀរសម្ងាប់ដើមចុងក្រោយ ល្បាយថ្នាំរំញោចអាចមានកំហាប់អេតេហ្វូន 5%។

ដើម្បីចៀសវាងការរំញោចលើសកម្រិតបរិមាណដែលបានកំណត់នៃរូបធាតុសកម្ម (ជាមីលីក្រាមសម្រាប់មួយដើមក្នុងមួយឆ្នាំ) មិនត្រូវឲ្យលើសជាដាច់ខាត។ បរិមាណនេះ គឺអាស្រ័យទៅតាមក្រុមក្លូនកៅស៊ូនិងប្រព័ន្ធចៀរ។

## ៣. ចំនួនជុំ (Rounds) នៃការរំញោច

ការរំញោចមួយលើក ទៅមួយលើកទៀតត្រូវមានគម្លាតពេលគ្រប់គ្រាន់ ដើម្បីទុកឲ្យដើមកៅស៊ូមានពេលអាចបង្កើតទឹកជ័រឡើងវិញ ស្របទៅតាមបរិមាណថ្នាំនិងប្រព័ន្ធចៀរដែលគេប្រើ។ ការរំញោចនេះត្រូវធ្វើច្រើនដង ឬ តិចក្នុងមួយឆ្នាំ គឺអាស្រ័យទៅតាមក្រុមក្លូន (Clonal typology)។

## ៤. ពេលត្រូវរំញោច

- ការរំញោចត្រូវប្រព្រឹត្តទៅ២៤-៤៨ម៉ោងមុនពេលចៀរលើកបន្ទាប់មកទៀត។

ការរំញោចលើសកំណត់ អាចធ្វើឲ្យមានវិបត្តិដល់សរីរៈនៃដើមកៅស៊ូនិងបណ្ដាលឲ្យដើមកៅស៊ូអន់ខ្សោយ ដែលអាចនាំឲ្យសម្បកស្ងួត ទឹកជ័រលែងហូរ និងនាំឲ្យមានបាតុភូតដែលគេហៅថា "ស្ងួតមុខចៀរ" (Tapping Panel Dryness)។

## ការប្រុងប្រយ័ត្ន

ក្នុងការរំញោច ត្រូវប្រុងប្រយ័ត្នដូចតទៅ ៖

- ★ ត្រូវចៀសវាងធ្វើការរំញោចក្នុងពេលដែលដើមកៅស៊ូកំពុងជ្រុះនិងដុះស្លឹកឡើងវិញ
- ★ មិនត្រូវលាបថ្នាំរំញោចនៅពេលភ្លៀង
- ★ ត្រូវរក្សាទុក ឬដឹកជញ្ជូនល្បាយសារធាតុរំញោចនៅក្នុងធុងមិនមែនលោហៈ៕

សូមទាក់ទងជាមួយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បើលោក-អ្នកចង់ដឹងលម្អិតអំពីការរំញោច។


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋាន: អគារលេខ ៩ មហាវិថី ប៉ែននុត (២៨៩) សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៨៨២ ៨៣១

សារអេឡិចត្រូនិច: crri@camnet.com.kh

វិបសាយ: www.crri.com.kh


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

បណ្ណបច្ចេកទេស

# ការរំញោចទឹកជ័រ ដោយប្រើអេតេហ្វូន




ការិយាល័យសរីរវិទ្យានិងអាជីវកម្ម
ខែតុលា ឆ្នាំ២០១២